**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ និង**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ ២៣៩១ ប្រក

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការបង្កើត និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងសេចក្តីសម្រេចនៃអង្គប្រជុំគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១០
- យោងសេចក្តីសម្រេចនៃអង្គប្រជុំគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ភូមិនៅតាមភូមិ នីមួយៗចំណុះឃុំ សង្កាត់។ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិសរសេរកាត់ថា “គ.អ.ភ”។

**ប្រការ ២.-**

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ជាគណៈកម្មាធិការមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវស្ថិតក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រការ ៣.-**

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មានសមាសភាពដូចខាងក្រោម ៖

- មេភូមិ ជាប្រធាន
- អនុប្រធានភូមិ ជាអនុប្រធាន
- សមាជិកភូមិ ជាលេខាធិការ

**ប្រការ ៤.-**

យោងតាមការចាំបាច់ក្នុងករណីនីមួយៗ និងតាមសំណើរបស់មេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចជ្រើសរើសប្រជាពលរដ្ឋមួយចំនួនជាសមាជិកគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។

**ប្រការ ៥.-**

មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត។

**ប្រការ ៦.-**

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ មានភារកិច្ចជួយក្រុមប្រឹក្សាឃុំ សង្កាត់លើការងារមួយចំនួនដូចតទៅ ៖

- ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សហគមន៍ និងឬតំណាងក្រុមមានផលប្រយោជន៍នានានៅក្នុងភូមិ ដើម្បីវិភាគ និងកំណត់បញ្ហាតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងភូមិដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ចូលរួមអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ តាមការណែនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ជួយតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់នៅក្នុងភូមិរបស់ខ្លួន

- បំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងសកម្មភាព និងដំណើរការអភិវឌ្ឍន៍ ព្រមទាំងកៀរគរធនធាន ដែលមានស្រាប់នៅក្នុងភូមិ
- បំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមក្នុងការថែទាំសមិទ្ធផលនានានៅក្នុងភូមិរបស់ខ្លួន
- ផ្សព្វផ្សាយពីការរីកចម្រើននៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងបទពិសោធន៍ល្អៗរបស់ខ្លួន
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្នុងការអនុវត្តគម្រោងនានានៅក្នុងភូមិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួន ជូនក្រុមប្រឹក្សាឃុំ សង្កាត់។

**ប្រការ ៧.-**

ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ គាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលឃុំ សង្កាត់ក្នុងការបង្កើត ការបណ្តុះបណ្តាលកសាងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។

**ប្រការ ៨.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចចេញសេចក្តីសម្រេចដើម្បីកំណត់អំពីរបៀបរបបការងារ និងតួនាទីភារកិច្ចជាក់ស្តែងបន្ថែមទៀតដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១០.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**រដ្ឋមន្ត្រី**
**ក្រសួងអភិវឌ្ឍន៍ជនបទ**

ជា សុផារ៉ា

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សមាជិក គ.ជ.អ.ប
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ